ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តពោធិ៍សាត់**

លេខ......ដ.ក/ព.ស

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខៈ..........
មកដល់ថ្ងៃទី......ខែ......ឆ្នាំ......
ម៉ោង..........

# ដីកា

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តពោធិ៍សាត់ ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨

## អភិបាល នៃគណៈអភិបាលខេត្ត

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៥៣២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ ២០១៥-២០១៨។
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលខេត្ត។

## សម្រេច

**ប្រការ ១.-**

- ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តពោធិ៍សាត់មានដូចខាងក្រោម ៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ម៉ៅ ធនិន** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២.លោក **ញឹម វណ្ណា** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |

សាលាខេត្តពោធិ៍សាត់ ភូមិពាលញែក II សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទូរស័ព្ទ : ០១២ ៩៥៩ ១២៦ / ០៥២ ៧៤៦ ៩៩៩ ទូរសារ : ០៥២ ៧៤៥ ៩៩៩
Email : pursat.info@gmail.com

| | | |
|---|---|---|
| ៣.លោក **ម៉ូច ម៉ានិត** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៤.លោក **ស៊ុន ហេង** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៥.លោក **ម៉ៅ នរិទ្ធ** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៦.លោក **សៅ ដារឿន** | អភិបាល នៃគណៈអភិបាលស្រុកបាកាន | សមាជិក |
| ៧.លោក **ផាយ ឡេង** | អភិបាល នៃគណៈអភិបាលស្រុកកណ្ដៀង | សមាជិក |
| ៨.លោក **ម៉ឹង វណ្ណា** | អភិបាល នៃគណៈអភិបាលស្រុកក្រគរ | សមាជិក |
| ៩.លោក **សូ សាហុង** | អភិបាល នៃគណៈអភិបាលស្រុកក្រវាញ | សមាជិក |
| ១០.លោក **ចាប នាង** | អភិបាល នៃគណៈអភិបាលក្រុងពោធិ៍សាត់ | សមាជិក |
| ១១.លោក **ហេង សុគាណា** | អភិបាល នៃគណៈអភិបាលស្រុកវាលវែង | សមាជិក |
| ១២.លោក **គុំ សំអុល** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | ជាមន្ត្រីបង្គោល |
| ១៣.លោក **អ៊ុន សម្ផស្ស** | មន្ត្រីមន្ទីរមុខងារសាធារណៈខេត្ត | ជាមន្ត្រីបង្គោល |

**ប្រការ ២.-**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- ជាអង្គភាពសម្របសម្រួលអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់រាល់ត្រីមាសទៅលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីដីកានេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយករដ្ឋបាលសាលាខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក ប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត និងសាមីខ្លួនដែលមានឈ្មោះដូចមានចែងក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ខេត្តពោធិ៍សាត់ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**ម៉ៅ ធនិន**

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រុមប្រឹក្សាខេត្ត

 ដើម្បីគោរពជូនជ្រាប

- ដូចប្រការ៤

 ដើម្បីសហការអនុវត្ត

- ឯកសារ-កាលប្បវត្តិ